# ឧបសម្ព័ន្ធ ១ - ប្រវត្តិនីតិវិធី

## ១. ការចាប់ខ្លួន ការបញ្ជូន និងការឃុំខ្លួនជនជាប់ចោទ

១. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ជនជាប់ចោទ នួន ជា ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ហើយត្រូវបានបញ្ជូនមកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក[១]។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជនជាប់ចោទ អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ហើយត្រូវបានបញ្ជូនមកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក[២]។ នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជនជាប់ចោទ ខៀវ សំផន ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ហើយត្រូវបានបញ្ជូនមកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក[៣]។ ការឃុំខ្លួនជនជាប់ចោទម្នាក់ៗជាបណ្ដោះអាសន្ន ត្រូវបានពន្យារថិរវេលាជាច្រើនដង[៤]។

## ២. ដំណាក់កាលនៃការស៊ើបសួរ

### ២.១ ការស៊ើបអង្កេតបឋម

២. សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតបឋមនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរលើជនសង្ស័យចំនួនប្រាំរូប ដែលក្នុងនោះមានជនជាប់ចោទទាំង ៤ រូប ខាងលើ រួមទាំង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច[៥] ផងដែរ។

---

[១] ដីកាបង្គាប់ឱ្យឃុំខ្លួន នួន ជា ឯកសារ C10 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧។

[២] ដីកាបង្គាប់ឱ្យឃុំខ្លួន អៀង សារី ឯកសារ C23 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ ដីកាបង្គាប់ឱ្យឃុំខ្លួន អៀង ធីរិទ្ធ ឯកសារ C21 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[៣] ដីកាបង្គាប់ឱ្យឃុំខ្លួន ខៀវ សំផន ឯកសារ C27 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[៤] *សូមមើល ឧ.* ដីកាសម្រេចអំពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ឯកសារ C9/6 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩។

[៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារ D3 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។

## ២.២ ដីកាសម្រេចបំបែកសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច (សំណុំរឿង ០០១)

៣. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចបំបែកសំណុំរឿង កាំង ហ្កេកអ៊ាវ ចំពោះអង្គហេតុចោទប្រកាន់ទាំងឡាយដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១[៦]។ កិច្ចស៊ើបសួរលើអង្គហេតុទាំងនេះត្រូវបានបិទ ហើយអង្គហេតុទាំងនេះត្រូវបានយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសដ[៧]។ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចលើកលែងការចោទប្រកាន់ដោយសម្រេចថា អំពើឧក្រិដ្ឋរបស់ កាំង ហ្កេកអ៊ាវ ត្រូវបានពិនិត្យចប់សព្វគ្រប់ហើយ ម្យ៉ាងទៀតការស៊ើបសួរលើសំណុំរឿង ០០២ ពុំបានបង្ហាញភ័ស្តុតាងថ្មីណាមួយពាក់ព័ន្ធនឹងការចូលរួមរបស់គាត់ឡើយ ហេតុដូច្នេះ គ្មានហេតុផលណាមួយត្រូវបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់នៅក្នុងសំណុំរឿង ០០២ នោះទេ[៨]។

## ២.៣ ការបិទកិច្ចស៊ើបសួរ និងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២

៤. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនានាអនុលោមតាមវិធាន ៦៦ (១) នៃវិធានផ្ទៃក្នុងថា សហចៅក្រមស៊ើបអង្កេតបានបិទកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២[៩]។ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានបញ្ជូន

---

[៦] ដីកាបំបែកសំណុំរឿង ឯកសារ D18 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧។

[៧] នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសំណុំរឿង ០០១ ដោយសម្រេចផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ៖ រឿងក្តី *កាំង ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការបស់ខ្លួនដោយបន្ថែមទោសលើ ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត៖ រឿងក្តី *កាំង ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជតក សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូល ឯកសារ F28 ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០។

[៨] ដីកាសម្រេចលើកលែងការចោទប្រកាន់ ឯកសារ D420 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០។

[៩] សេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ ឯកសារ D317 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០។

សំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង[១០]។ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[១១]។

៥. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២ ដោយសម្រេចថា មានភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថាជនជាប់ចោទ នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ (រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬ ឲ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេស និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់) និងការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា អនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[១២]។

## ២.៤ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

៦. ក្រុមមេធាវីការពារក្តីទាំងអស់ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[១៣]។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសាលដីកាចំនួនបី លើបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ ដោយបានកែប្រែពីរចំណុចនៅក្នុងដីកាដំណោះស្រាយ និងច្រានចោលមូលដ្ឋានផ្សេង

---

[១០]ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ឯកសារ D385 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០។

[១១]ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ឯកសារ D390 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០។

[១២] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៦១៣។

[១៣]បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/3/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/4/3 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។

ទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍ ដោយបានបញ្ជាក់ថា សំអាងហេតុពេញលេញនឹងត្រូវផ្តល់ជូននាពេលក្រោយ[១៤]។ សាលដីកាដែលមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ត្រូវបានចេញនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១[១៥] នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[១៦] និងនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១[១៧]។ អង្គបុរេជំនុំជម្រះបានសម្រេចថា នៅក្នុងអំឡុងពេលដែលស្ថិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានតម្រូវឲ្យមានចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ[១៨]។ អង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមទៀតថា នៅក្នុងរយៈពេលពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយឡែកតែឯងនោះទេ ហើយបានលុបចោលការរំលោភផ្លូវភេទចេញពីដីកាដំណោះស្រាយ ដោយកត់សម្គាល់ថា អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់នៃការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[១៩]។ ដីកាដំណោះស្រាយពុំត្រូវបានចេញសាជាថ្មីដោយដាក់បញ្ចូលចំណុចកែប្រែទាំងនេះនោះឡើយ ហេតុដូច្នេះហើយ ដីកាដំណោះស្រាយនេះ ត្រូវតែយកមកអានភ្ជាប់ជាមួយនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ។

---

[១៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

[១៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[១៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/15 និង D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

[១៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។

[១៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/3/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៦។

[១៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/3/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៦។

# ៣. ដើមបណ្តឹងរដ្ឋប្បវេណី

## ៣.១ ការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៧. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេត បានសម្រេចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១២៣ បណ្តឹង[២០]។ បណ្តឹងឧទ្ធរណ៍ចំនួន ៩៤ ត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ជំនួសឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៧៤៧ នាក់ ដែលពីដំបូងត្រូវបានបដិសេធឋានៈជាដើមបណ្តឹង-រដ្ឋប្បវេណី[២១]។ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ ហើយបានច្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ទើរតែទាំងអស់ ដោយផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់អ្នកដាក់ពាក្យសុំចំនួន ១.៧២៨ នាក់បន្ថែមទៀត[២២]។ ចៅក្រម Marchi-Uhel បានជំទាស់ទៅលើផ្នែកមួយ ដោយគាត់យល់ឃើញថាការពិនិត្យបណ្តឹងឧទ្ធរណ៍*ជាថ្មីម្តងទៀត (de novo)* ដែលធ្វើឡើងដោយចៅក្រមភាគច្រើននោះ គឺមិនមានភាពចាំបាច់នោះទេ តែគាត់យល់ស្របជាមួយនឹងចៅក្រមភាគច្រើនដែលថាបណ្តឹងឧទ្ធរណ៍ទាំងនោះ គឺអាចទទួលយកបាន[២៣]។ នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បាន

---

[២០] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១២។ សម្រាប់បញ្ជីទាំងមូល *សូមមើល* ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D427.1 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។

[២១] *សូមមើល* ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅក្រៅប្រទេសកម្ពុជា ឯកសារ D404/2 ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១០។ ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋានបច្ចុប្បន្ននៅខេត្តកំពង់ឆ្នាំង ឯកសារ D417/2 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០។

[២២] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D404/2/4 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D411/3/6 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

[២៣] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D404/2/4 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត

ពិនិត្យមើលសាជាថ្មី អំពីការបដិសេធរបស់ខ្លួនលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ហើយបានសម្រេចផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់អ្នកដាក់ពាក្យសុំចំនួន ១២ នាក់បន្ថែមទៀត[២៤]។

៨. នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៩ នាក់បានបង្កើតជាបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីតែមួយ ដោយមានសហមេធាវីនាំមុខពីររូប (លោក ពេជ្រ អង្គ និងលោកស្រី Elisabeth SIMONNEAU-FORT) ត្រូវបានចាត់តាំងឲ្យធ្វើជាតំណាង[២៥]។ នាពេលបច្ចុប្បន្ននេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ មានចំនួន ៣.៨៦៧ នាក់។ បណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាពនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ មានករណីមួយចំនួនត្រូវបានបន្តដោយសិទ្ធិវ័ន្តរបស់ពួកគេ បន្ទាប់ពីមានការយល់ព្រមជាផ្លូវការពីអង្គជំនុំជម្រះសាលាដំបូង[២៦]។ ចាប់តាំងពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤ លោកស្រី Elisabeth SIMONNEAU-FORT បានលាលែងពីដំណែង

---

លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D411/3/6 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

[២៤] សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញ អំពីការទទួលយកពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D250/3/2/1/8 ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១។ *សូមមើលផងដែរ* សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី (អ.ប.ជ) ឯកសារ D364/1/6 ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១១។

[២៥] ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៣។

[២៦] *សូមមើល ឧ.* ការបន្តបណ្តឹងរដ្ឋប្បវេណីដោយសិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាពនៅក្នុងសំណុំរឿង ០០២ (អ.ជ.ស.ដ) ឯកសារ E2/20 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣។ ការបន្តសិទ្ធិបណ្តឹងរដ្ឋប្បវេណី វ៉ាន់ សារី ដែលបានទទួលមរណភាពនៅក្នុងសំណុំរឿង ០០២ (អ.ជ.ស.ដ) ឯកសារ E2/22/1 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣។ ការបន្តសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E/26/1៖ សំណើសុំបន្តសំណុំបែបបទដើមបណ្តឹងរដ្ឋប្បវេណីរបស់ អៀង ស៊ីផាច ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៤ ការបន្តសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីពីឈ្មោះ ម៉ៅ សុន ដែលបានទទួលមរណភាព ក្នុងសំណុំរឿង ០០២ ឯកសារ E2/24/1 ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ ការបន្តសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ឈ្មោះ មៀច ប៊ុណ្ណា ដែលបានទទួលមរណភាព ឯកសារ E2/29/1 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤។ មានដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់បានដកខ្លួនចេញពីសំណុំរឿង។

ហើយលោកស្រី Marie GUIRAUD ត្រូវបានចាត់តាំងជាសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤។[២៧]

## ៣.២ សំណង

៩. អាស្រ័យទៅលើការពិភាក្សាបន្ថែមនៅពេលក្រោយទៀត នៅក្នុងខែ មិថុនា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាពួកគេមានបំណងស្នើសុំសំណងចំនួនបួនប្រភេទ៖ (i) ការសាងសង់ស្តូប (ii) គម្រោងស្តារនីតិសម្បទា (iii) ការចងក្រងបញ្ជីឈ្មោះជនរងគ្រោះ និងគម្រោងអប់រំ និង (iv) សំណងផ្សេងៗទៀត[២៨]។

១០. ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១ អាចផ្តល់សំណងប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះ ប្រសិនបើរកឃើញថាជនជាប់ចោទមានពិរុទ្ធ អង្គជំនុំជម្រះសាលាដំបូងបានស្នើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យកំណត់ និងរៀបចំសម្រាប់ការអនុវត្តសំណងជាអាទិភាពមួយចំនួនតូច ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន[២៩]។ នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៣ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានកំណត់គម្រោងជាអាទិភាពចំនួនប្រាំពីរ៖ (i) គម្រោងទិវាជាតិនៃការចងចាំ (ii) គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រម្លឹកជាសាធារណៈ (iii) គម្រោងកម្មវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម (iv) ក្រុមជួយខ្លួនឯង (v) គម្រោងតាំងពិពណ៌ និងអប់រំចល័ត (vi) គម្រោងតាំងពិពណ៌ជាអចិន្ត្រៃយ៍ (vii) សៀវភៅស្តីពីអង្គហេតុដែលត្រូវបានវិនិច្ឆ័យរួច និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក[៣០]។ នៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៣ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ-

---

[២៧] ពាក្យសុំលាលែងពីការងាររបស់ លោកស្រី SIMONNEAU-FORT ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤, PAS-សេចក្តីប្រកាសព័ត៌មាន៖ Marie GUIRAD ត្រូវបានចាត់តាំងជាសហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤។

[២៨] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ១០៧-១១៤។

[២៩] ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ *ស្ទួន* (៤)) (អ.ជ.ស.ដ) ឯកសារ E218/7 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២។

[៣០] ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ *ស្ទួន* (៤)) ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់បំផុត ឯកសារ E218/7/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១២។

ប្បវេណីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីមូលនិធិដែលបានស្នើសុំសម្រាប់គម្រោងនីមួយៗ ហើយបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យកត់សម្គាល់អំពីគម្រោងមួយបន្ថែមទៀតៈ (viii) ជំពូកមួយនៃសៀវភៅសិក្សា ដោយដាក់បញ្ចូលនូវការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃទៅក្នុងកម្មវិធីសិក្សា[៣១]។ នៅក្នុងសំណើសុំចុងក្រោយស្តីពីសំណងរបស់ខ្លួន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងអំពីសំណើសុំរបស់ពួកគេសាជាថ្មីលើគម្រោងទាំងនេះ ហើយបានធ្វើសំណើសុំថ្មីៗបន្ថែមទៀតពាក់ព័ន្ធនឹង (ix) ការសាងសង់ស្តូបនៅរាជធានីភ្នំពេញសម្រាប់ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំ (x) ការសាងសង់ស្តូបសម្រាប់រម្លឹកដល់ជនរងគ្រោះនៃរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរដែលរស់នៅប្រទេសបារាំង (xi) ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព (xii) ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមនៃសំណុំរឿង ០០២/០១ ទាំងមូល និងសង្ខេប និង (xiii) ការផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក[៣២]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានការយល់ព្រមលើគម្រោងសរុបចំនួន១៣។

## ៤. កិច្ចដំណើរការនីតិវិធីជំនុំជម្រះ

១១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងបច្ចុប្បន្ន នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ បន្ទាប់ពីអង្គបុរេជំនុំជម្រះ បានដោះស្រាយលើបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះ-ស្រាយ[៣៣]។

---

[៣១] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E218/7/2) ទាក់ទងទៅនឹងគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/3 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣។

[៣២] សំណើសុំចុងក្រោយស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E218/7/6 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។

[៣៣] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ទំព័រ ២។

## ៤.១ ការរៀបចំការជំនុំជម្រះ

### ៤.១.១ អញ្ញត្រកម្ម

១២. នៅថ្ងៃទី ០៨ និងថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ជនជាប់ចោទម្នាក់ៗបានដាក់អញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ នីត្យានុកូលភាពនៃវិធានផ្ទៃក្នុង អាជ្ញាយុកាលនៃបទល្មើសជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[៣៤]។ នៅថ្ងៃទី ២៧

[៣៤] បណ្តឹងលើអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូង ឯកសារ E36 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង និងអានុភាពនៃដីការបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E42 ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ឯកសារ E44 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មលើយុត្តាធិការ ឯកសារ E46 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មស្តីពីការរលត់បណ្តឹងអាជ្ញា (បទល្មើសជាតិ) ឯកសារ E47 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ បណ្តឹងអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង របស់ អៀង សារី (វិធាន ៨៩(១)(គ)) ឯកសារ E48 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង របស់ អៀង សារី (អាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មរួមបញ្ចូលគ្នា ឯកសារ E51/3 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ *សូមមើលផងដែរ* ចម្លើយតបរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ឯកសារ E51/5/4 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ឯកសារ E51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១។ ការបង្ហាញរបស់ អៀង សារី លើផ្នែកនៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយដែលតម្រូវឲ្យមានសារណាបន្ថែមទាក់ទងនឹងការអនុវត្តនៅ អ.វ.ត.ក នូវឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ ឯកសារ E83 ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១។ សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)) ឯកសារ E51/11 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១។ សារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (ការលើកលែងទោស និងការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ) ឯកសារ E51/10 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) ឯកសារ E51/11/1 ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (ការអនុគ្រោះទោស និងការលើកលែងទោស) ឯកសារ E51/10/3 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបន្ថែមរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង(*គោលការណ៍គ្មានការកាត់ទោសពីរដង*

ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបន្ថែម ពាក់ព័ន្ធនឹងអាជ្ញាយុកាល នៃបទល្មើសជាតិ[៣៥]។ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១ ជនជាប់ចោទ អៀង សារី បានដាក់សំណើសុំការអនុញ្ញាត ដើម្បីដាក់សារណាបន្ថែមរបស់ខ្លួនចំពោះអញ្ញត្រកម្មតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ស្តីពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិ[៣៦]។

១៣. ក្នុងរយៈពេលប៉ុន្មានខែបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហាអញ្ញត្រ-កម្មនានា ដែលអង្គជំនុំជម្រះយល់ឃើញថា អញ្ញត្រកម្មទាំងនោះគឺជាឧបសគ្គដ៏ធំដែលរារាំងដល់ការចាប់ផ្តើមការជំនុំជម្រះ[៣៧]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អង្គជំនុំជម្រះបានទទួលសំណុំរឿង ដែលពុំមានសុពលភាពពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលមាននៅក្នុងផ្នែកនៃសេចក្តីសម្រេចនៃដីកា-

---

*ចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ) ឯកសារ E51/13 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១។

[៣៥] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ ឯកសារ E51/7/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។ សូមមើលផងដែរ ចម្លើយតបរបស់ជនជាប់ចោទ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអាជ្ញាយុកាលចំពោះបទល្មើសជាតិ ឯកសារ E51/7/3 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ។ ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអាជ្ញាយុកាលចំពោះបទល្មើសជាតិ ឯកសារ E51/7/2 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

[៣៦] សំណើរបស់ អៀង សារី សុំការអនុញ្ញាតដើម្បីដាក់សារណាបន្ថែមរបស់ខ្លួនចំពោះអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (បទល្មើសជាតិ) ឯកសារ E94 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១។

[៣៧] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ឯកសារ E51/14 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ឯកសារ E51/15 ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១។ សេចក្តីសន្និដ្ឋានផ្សេងទៀត ដែលត្រូវបានភាគីចាត់ទុកថាជាអញ្ញត្រកម្ម ត្រូវបានអង្គជំនុំជម្រះសម្រេចថាមានលក្ខណៈសមស្រប សម្រាប់ដំណោះស្រាយនៅក្នុងសាលក្រម ឬទុកយកទៅជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ នាពេលក្រោយ ដោយសារសេចក្តីសន្និដ្ឋានទាំងនេះពាក់ព័ន្ធនឹងបញ្ហានានាដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ (ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១)។

ដំណោះស្រាយក្នុងសំណុំរឿង ០០២។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះពុំមានមូលដ្ឋានជំនុំជម្រះជនជាប់ចោទចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិឡើយ[៣៨]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចច្រានចោលអញ្ញត្រកម្មរបស់ជនជាប់ចោទ នួន ជា ស្តីពីសុពលភាពនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[៣៩]។ ក្រោយមក អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[៤០]។

១៤. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៤១] ដែលសំណើសុំនេះត្រូវបានគាំទ្រដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[៤២]។ ទោះបីជាយ៉ាងនេះក្តី ជនជាប់ចោទ អៀង ធីរិទ្ធ នួន ជា ខៀវ សំផន និង អៀង សារី បានស្នើសុំទាំងអស់គ្នាឱ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើសុំនេះ[៤៣]។

---

[៣៨] សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទល្មើសជាតិ) ឯកសារ E122 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២១-២៣។

[៣៩] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ឯកសារ E51/14 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១។

[៤០] សេចក្តីសង្ខេបដែលមានសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារ E116/1/6 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២។

[៤១] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់-អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។ *សូមមើលផងដែរ* សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ពាក់ព័ន្ធនឹងបញ្ហា ថាតើសហព្រះរាជអាជ្ញាអាចស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទនៅក្នុងដំណាក់កាលនេះនៃនីតិវិធីដែរឬអត់ និងសំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់ ឯកសារ E103 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

[៤២] សារណាឆ្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការគាំទ្រសំណើរបស់សហព្រះរាជ-អាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

[៤៣] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់

នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាដោយសម្រេចថា អង្គជំនុំជម្រះសាលាដំបូង ពុំមានមូលដ្ឋានដើម្បីពិចារណាសាជាថ្មីលើសេចក្តីសម្រេចរបស់ខ្លួននៅក្នុងសំណុំរឿង ០០១ និងសម្រេចថា ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ពុំមែនជាផ្នែកមួយនៃនិយមន័យនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងអំឡុងពេលដែលតុលាការនេះមានយុត្តាធិការក្នុងពេលវេលានោះឡើយ[៤៤]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ អៀង សារី ដែលប្តឹងប្រឆាំងនឹងសេចក្តីសម្រេចនេះ[៤៥]។

---

មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E99/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារ E100/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E95/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ឯកសារ E95/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[៤៤] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់-ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/8 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១។

[៤៥] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (អ.ជ.ត.ក) ឯកសារ E95/8/1/4 ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/8/1/1 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ការចុះបញ្ជីបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

១៥. នៅក្នុងខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងទៅនឹងអង្គហេតុនានា នៅក្នុងដីកាដំណោះស្រាយដែលបង្កើតបាន ជាការរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាង កំណត់ថាជា អំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៤៦]។ អង្គជំនុំជម្រះ សាលាដំបូងបានសម្រេចថា បញ្ហានេះមិនទាន់ត្រូវសម្រេចនៅពេលនេះទេ ក្រោយពីពិចារណាលើ វិសាលភាពនៃការជំនុំជម្រះលើកទីមួយ ដូចបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពី មានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ដោយទុកបញ្ហានេះយកទៅសម្រេចនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលក្រោយៗទៀត[៤៧]។

---

លើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់-អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/8/1 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៤៦] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E99 ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារ E99/1 ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះ-រាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ឯកសារ E100/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ឯកសារ E99/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់ លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជ-អាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ឯកសារ E99/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E99/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[៤៧] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៩ ។

១៦. នៅក្នុងខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជាទម្រង់នៃការទទួលខុសត្រូវ ដែលមានសុពលភាពនៅចំពោះមុខ អ.វ.ត.ក និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មី តាមករណីសមស្រប ថាជាឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត អនុលោមតាមទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម នៅពេលអង្គជំនុំជម្រះចេញសាលក្រម[៤៨]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគាំទ្រសំណើសុំនេះ ទោះបីជាជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង គួរច្រានចោល សំណើសុំនេះក្តី[៤៩]។ នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចច្រានចោលសំណើសុំនេះ ដោយលើកឡើងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីបីពុំបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងពុំមែនជាគោលការណ៍ទូទៅនៃច្បាប់ នៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២ នោះឡើយ[៥០]។

១៧. បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូង បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង ០០២ រួចមក នៅក្នុងខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចព្យួរអញ្ញត្រកម្មមួយចំនួនដោយទុកយកទៅសម្រេចនៅក្នុងដំណាក់កាលក្រោយ[៥១]។

---

[៤៨] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ឯកសារ E100 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

[៤៩] សារណាគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជា ទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ឯកសារ E100/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ឯកសារ E100/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមនៃទម្រង់ទីបី ឯកសារ E100/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E100/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[៥០] សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៣១, ៣៥-៣៨។

[៥១] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ។

១៨. នៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលអញ្ញត្រកម្មរបស់ អៀង សារី ពាក់ព័ន្ធនឹង*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (គោលការណ៍គ្មានការកាត់ទោសពីរដង) និងការលើកលែងទោស[៥២]។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសមិនទទួលយកបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ អៀង សារី[៥៣]។

១៩. នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះបានសម្រេចលើអញ្ញត្រកម្មទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងការរៀបចំការជំនុំជម្រះ សម្រាប់សំណុំរឿង ០០២/០១ រួចរាល់ហើយ[៥៤]។

### ៤.១.២ សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ

២០. នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ នួន ជា និង អៀង ធីរិទ្ធ បានស្នើសុំឲ្យតែងតាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់ពួកគេក្នុងការចូលរួមសវនាការ[៥៥] ហើយអង្គជំនុំជម្រះបានតែងតាំងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រនៅក្នុងខែ មេសា ឆ្នាំ ២០១១ និងបង្គាប់ឲ្យធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រលើជនជាប់ចោទ អៀង សារី ផងដែរ ក្រោយពីមានសំណើសុំឲ្យដំណើរការសវនាការជំនុំជម្រះក្ដីរយៈពេលកន្លះថ្ងៃជារៀងរាល់ថ្ងៃសវនាការ ដោយសារតែអាយុ និងសុខភាពមិនល្អរបស់

[៥២] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ *Ne Bis in Idem* និងការលើកលែងទោស និងការអនុគ្រោះទោស) ឯកសារ E51/15 ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ២៧, ៣០-៣៦។

[៥៣] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីអញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ *Ne Bis in Idem* និងការលើកលែងទោស និងការអនុគ្រោះទោស) (អ.ជ.ត.ក) ឯកសារ E51/15/1/2 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។

[៥៤] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៥៥] សំណើជាបន្ទាន់សុំចាត់តាំងអ្នកជំនាញផ្នែកសម្បទា ឯកសារ E30 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណើរបស់មេធាវីការពារក្ដីស្នើសុំចាត់តាំងអ្នកជំនាញផ្នែកវិកលចរិត (Neuropsychiatrist) ដើម្បីវាយតម្លៃសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសនវការ ឯកសារ E52 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។

គាត់[៥៦]។ ជនជាប់ចោទ ខៀវ សំផន ពុំបានតវ៉ាលើបញ្ហាសម្បទារបស់គាត់ក្នុងការចូលរួមសវនាការនោះទេ[៥៧]។ អ្នកជំនាញបានចេញរបាយការណ៍ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី នួន ជា និង អៀង ធីរិទ្ធ។ សវនាការមួយស្ដីពីសម្បទារបស់ជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការត្រូវបានធ្វើឡើងពីថ្ងៃទី ២៩ ដល់ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១[៥៨]។

២១. ជនជាប់ចោទ អៀង សារី ពុំបានជំទាស់តវ៉ាលើរបាយការណ៍របស់អ្នកជំនាញដែលបានសន្និដ្ឋានថាជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះទេ ក៏ប៉ុន្តែ បានផ្តល់អនុសាសន៍ឲ្យមានវិធានការមួយចំនួនដើម្បីធ្វើឲ្យគាត់មានភាពងាយស្រួល និងផ្តល់អារម្មណ៍បានប្រសើរឡើង[៥៩]។ សុខភាពរបស់ជនជាប់ចោទ អៀង សារី ត្រូវបានធ្វើការវាយតម្លៃឡើងវិញនៅក្នុងខែ តុលា ឆ្នាំ ២០១២ ហើយនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គាត់នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយក្រោយមក អង្គជំនុំជម្រះបានច្រានចោលសំណើសុំឲ្យពិចារណាសេចក្តីសម្រេចនេះឡើងវិញ[៦០]។

---

[៥៦] ដីកាចាត់តាំងអ្នកជំនាញ ឯកសារ E62/3 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១។ សូមមើល *ផងដែរ* ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ ឯកសារ E20 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១១។

[៥៧] ដីកាកំណត់កាលបរិច្ឆេទសវនាការស្ដីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឯកសារ E110 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១។

[៥៨] របាយការណ៍អ្នកជំនាញថែទាំមនុស្សចាស់លើ នួន ជា ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E62/3/4 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១។ របាយ-ការណ៍អ្នកជំនាញថែទាំមនុស្សចាស់លើ អៀង សារី ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E62/3/5 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១។ របាយ-ការណ៍អ្នកជំនាញថែទាំមនុស្សចាស់លើ អៀង ធីរិទ្ធ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E62/3/6 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១។

[៥៩] ដីកាកំណត់កាលបរិច្ឆេទសវនាការស្ដីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឯកសារ E110 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១។

[៦០] សេចក្តីសម្រេចលើសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារ E238/9 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើសំណើររបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២។

## ៤.១.២.១ សម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

២២. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រោយពីពិនិត្យមើលរបាយការណ៍របស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងក្រោយពីបានស្តាប់ភាគីលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[៦១]។ ទោះបីជាយ៉ាងនេះក្តី នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ជនជាប់ចោទ នួន ជា មានជំងឺប្រចាំកាយ ហើយបានបង្គាប់ឱ្យអ្នកជំនាញផ្នែកវេជ្ជសាស្ត្រចំនួនពីររូប ធ្វើការវាយតម្លៃឡើងវិញលើសុខភាពរបស់គាត់[៦២]។ ផ្អែកតាមរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានតម្កល់សេចក្តីសម្រេចនាពេលមុនរបស់ខ្លួន ដោយបញ្ជាក់ឡើងវិញថា ជនជាប់ចោទ នួន ជា មានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យក្នុងការការពារខ្លួនគាត់ ហេតុដូច្នេះហើយ ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[៦៣]។

## ៤.១.២.២ សម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

២៣. នៅថ្ងៃទី ១៩ និងថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ក្នុងពេលធ្វើសវនាការជាសាធារណៈ ភាគីនានា បានបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញស្តីពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ហើយបានសួរសំណួរដោយផ្ទាល់ទៅកាន់អ្នកជំនាញ[៦៤]។

---

[៦១] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៦២] ការតែងតាំងជាថ្មីនូវអ្នកជំនាញដើម្បីពិនិត្យឡើងវិញអំពីសុខភាព និងសម្បទារបស់ អៀង សារី និង នួន ជា ក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E256 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១-២។

[៦៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២។ សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៣។

[៦៤] ដីកាកំណត់កាលបរិច្ឆេទសវនាការដែលនឹងត្រូវធ្វើនៅថ្ងៃទី ១៩ - ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E129 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/11.1 ទំព័រ ៨០-១៣១ ។ ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/12.1 ទំព័រ ២-២៩ និងទំព័រ ៧៣-៨១ ទំព័រ ៣០-៥៦ ទំព័រ ៥៧-៦៩។ ភាគីក៏បានធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានៃការបំបែកកិច្ចដំណើរការនីតិវិធីលើរឿងក្តីប្រឆាំងនឹង អៀង ធីរិទ្ធ ចេញពីសំណុំរឿង ០០២ ផងដែរ។

២៤. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាឯកច្ឆ័ន្ទថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះទេ។ អង្គជំនុំជម្រះបានបង្គាប់ឲ្យបំបែកបទចោទ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ព្រមទាំងបង្គាប់ឲ្យដោះលែងគាត់ដោយគ្មានលក្ខខណ្ឌ[៦៥]។ នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដោយសម្រេចថា ការដោះលែងដោយគ្មានលក្ខណ្ឌ គឺជាការពុំសមស្របដោយសារមានលទ្ធភាពថា សុខភាពរបស់ជនជាប់ចោទអាចប្រសើរឡើងវិញ ហើយនៅពេលនោះ អាចអនុញ្ញាតឲ្យលុបចោលការផ្អាកកិច្ចដំណើរការនីតិវិធីវិញបាន។ អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់អង្គជំនុំជម្រះសាលាដំបូងឲ្យស្នើសុំការព្យាបាលផ្នែកវេជ្ជសាស្ត្របន្ថែមសម្រាប់ជនជាប់ចោទ អៀង ធីរិទ្ធ និងឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រដោយអ្នកជំនាញក្នុងរយៈពេល ០៦ ខែ ក្រោយពីការព្យាបាលនេះ ដើម្បីកំណត់អំពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[៦៦]។

២៥. បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃឡើងវិញលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការក្រោយពីបានតែងតាំងអ្នកជំនាញ ដែលបានធ្វើរបាយការណ៍ថាជំងឺវង្វេងវង្វាន់ស្មារតីរបស់គាត់បានវិវត្ត ហើយថាគ្រប់មធ្យោបាយព្យាបាលទាំងអស់បានប្រើប្រាស់រួចហើយ។ នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចតម្កល់សេចក្តីសម្រេចរបស់ខ្លួនថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការទេ ហើយបានសម្រេចតម្កល់ការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់នៅក្នុងសំណុំរឿង ០០២ ។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌចេញពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[៦៧]។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនេះ

---

[៦៥] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៦៦] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (អ.ជ.ត.ក) ឯកសារ E138/1/7 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១។

[៦៧] សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២។

ដោយហេតុថា សេចក្តីសម្រេចនេះពុំបានដាក់លក្ខខណ្ឌលើការដោះលែងជនជាប់ចោទ[៦៨]។ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេច ទទួលយកផ្នែកខ្លះនៃសំណើសុំរបស់សហព្រះរាជអាជ្ញា និងបានបង្គាប់ឲ្យដោះលែងជនជាប់ចោទស្ថិតក្រោមលក្ខខណ្ឌមួយចំនួន រហូតដល់មានសេចក្តីសម្រេចពេញលេញលើបណ្តឹងសាទុក្ខនេះ[៦៩]។ ជនជាប់ចោទ អៀង ធីរិទ្ធ ក៏ត្រូវបានដោះលែងនៅថ្ងៃនោះដែរ។

២៦. ក្រោយពីសហព្រះរាជអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានបន្ថែមជាលាយលក្ខណ៍អក្សរ ស្តីពីលក្ខខណ្ឌនៃការដោះលែងនេះ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការលើបណ្តឹងសាទុក្ខនេះនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ ហើយបានបង្គាប់ឲ្យមានរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ រួមទាំងការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រទៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងការត្រួតពិនិត្យផ្នែកសន្តិសុខមួយខែម្តង ដោយមន្ត្រីនគរបាលយុត្តិធម៌[៧០]។ បន្ទាប់ពីក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ បានស្នើសុំការបញ្ជាក់បំភ្លឺអំពីការបកស្រាយ និងការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[៧១] នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណើសុំនេះទៅអង្គជំនុំ-ជម្រះតុលាការកំពូល ដើម្បីបញ្ជាក់បំភ្លឺថាតើបុគ្គលណាខ្លះនឹងទទួលបន្ទុកចំណាយលើការវាយតម្លៃ

---

[៦៨] បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតី របស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10/1/1 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។

[៦៩] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/10/1/2/1 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២។

[៧០] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (អ.ជ.ត.ក) ឯកសារ E138/1/10/1/5/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។

[៧១] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (អ.ជ.ត.ក) ឯកសារ E138/1/10/1/5/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។ សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺពីការអនុវត្ត "សេចក្តីសម្រេចលើបណ្តឹង-សាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ" របស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ E138/1/10/1/5/8 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣។

ផ្នែកវេជ្ជសាស្ត្រ ព្រមទាំងទណ្ឌកម្មសមស្របក្នុងករណីជនជាប់ចោទបំពានលើលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ[៧២]។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជូនបញ្ហានេះមកអង្គជំនុំជម្រះសាលាដំបូងវិញ ជាមួយនឹងការណែនាំអំពីការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ[៧៣]។ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង ធីរិទ្ធ អំពីវិធានការសម្រាប់ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល រួមទាំងការណែនាំជាក់លាក់ពាក់ព័ន្ធនឹងសេចក្ដីជូនដំណឹងអំពីការផ្លាស់ប្ដូរអាសយដ្ឋាន និង/ឬ ការធ្វើដំណើរទៅក្រៅប្រទេស ការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងរបាយការណ៍ស្ដីពីការអនុវត្តតាមលក្ខខណ្ឌ[៧៤]។ នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញម្នាក់ដើម្បីអនុវត្តការវាយតម្លៃឡើងវិញ អំពីស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ នៅរៀងរាល់ប្រាំមួយខែម្ដង[៧៥]។ អ្នកជំនាញបានរាយការណ៍ថា ស្ថានភាពរបស់គាត់បានធ្លាក់ចុះជាងមុន ចាប់តាំងពីពេលវាយតម្លៃលើកចុងក្រោយមក[៧៦]។

### ៤.១.២.៣ មរណភាពរបស់ជនជាប់ចោទ អៀង សារី

២៧. ជនជាប់ចោទ អៀង សារី បានទទួលមរណភាព នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣[៧៧]។ អនុលោមតាមមាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មរណភាពរបស់

---

[៧២] សេចក្ដីសម្រេចស្ដីពីការអនុវត្តនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ឯកសារ E138/1/10/1/5/8/1 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣។

[៧៣] សេចក្ដីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្ដី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ (អ.ជ.ត.ក) ឯកសារ E138/1/10/1/5/8/2 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣។

[៧៤] សំណើរបស់មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺពីការអនុវត្តនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ឯកសារ E138/1/10/1/5/8 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣។

[៧៥] ការតែងតាំងវេជ្ជបណ្ឌិតដើម្បីអនុវត្តន៍ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រលើ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្ដង (អ.ជ.ស.ដ) ឯកសារ E138/1/10/1/5/9 ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣។

[៧៦] ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រមកលើ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្ដង ដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ E138/1/10/1/5/9/2 កថាខណ្ឌ ២៦។

[៧៧] លិខិតមរណភាពរបស់ អៀង សារី ឯកសារ E270 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

ជនជាប់ចោទ មានអានុភាពរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងគាត់នៅចំពោះមុខ អ.វ.ត.ក[៧៨]។

### ៤.១.៣ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ

២៨. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ[៧៩]។ ភាគីនានាបានដាក់បញ្ជីរបស់ពួកគេជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានខែក្រោយមក [៨០]។

[៧៨] សេចក្តីសម្រេចលើការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ឯកសារ E270/1 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[៧៩] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[៨០] *សូមមើល ឧ.* បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ ទី២ ទី៣ ទី៣ក ទី៤ និងទី៥ ឯកសារ E9/4 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។ បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់ អៀង សារី និងសេចក្តីជូនដំណឹងរបស់ អៀង សារី ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ឯកសារ E9/4/2 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង រួមទាំងឧបសម្ព័ន្ធសម្ងាត់១ ២ក ២ខ ក៣ ៣ខ និង៤ ឯកសារ E9/4/3 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ឯកសារ E9/4/4 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ បញ្ជីឈ្មោះសាក្សី និង អ្នកជំនាញរបស់ អៀង ធីរិទ្ធ ឯកសារ E9/4/5 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ បញ្ជីឈ្មោះសាក្សី និង អ្នកជំនាញដែលបានស្នើឡើង ឯកសារ E9/4/6 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។ សេចក្តីសង្ខេបអំពីអ្នកជំនាញ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ឯកសារ E9/13 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ សេចក្តីសង្ខេប និងគុណវុឌ្ឍិរបស់អ្នកជំនាញជាមួយនឹងចំណុចនៃការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E9/8 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ (ជាភាសាអង់គ្លេស និងខ្មែរ និងនៅថ្ងៃទី ២៨ ខែ កុម្ភៈ ជាភាសាបារាំង)។ សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ឯកសារ E9/10 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ សេចក្តីសង្ខេបរបស់ អៀង សារី អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ស្តីពីជំនាញ និងគុណវុឌ្ឍិរបស់អ្នកជំនាញម្នាក់ៗដែលបានស្នើឡើង និងចំណុចនៃការចោទប្រកាន់ដែលអ្នកជំនាញម្នាក់ៗរំពឹងថានឹងមកផ្តល់សក្ខីកម្ម ឯកសារ E9/12 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ បញ្ជាលំអិតបន្ថែមទៀតដែលពាក់ព័ន្ធទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើង ឯកសារ E9/11 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ ព័ត៌មានបន្ថែមរបស់ អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញ ឯកសារ E9/9 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ ញត្តិរបស់ អៀង សារី គាំទ្រ

២៩. នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីនានាថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័សរបស់ពួកគេ តម្រូវឲ្យអង្គជំនុំជម្រះកាត់បន្ថយចំនួនសាក្សីជាច្រើននាក់ដែលនឹងត្រូវកោះហៅមកចំពោះមុខអង្គជំនុំជម្រះ ហើយបានបង្គាប់ឲ្យភាគីនានាបញ្ជាក់នៅត្រឹមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ អំពីសាក្សីដែលពួកគេពិចារណាឃើញថា ជាប់ពាក់ព័ន្ធបំផុតជាមួយនឹងប្រធានបទ៤ដំបូងដែលបានប្រកាសនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ[៨១]។ ភាគីនានាបានផ្តល់បញ្ជីកែសម្រួលរបស់ពួកគេ ជូនមកអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ១៤ ថ្ងៃទី ២០ និងថ្ងៃទី ២១ ខែ មិថុនា ដាច់ដោយឡែកពីគ្នា[៨២]។ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់បញ្ជីកែសម្រួលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងអង្គហេតុសម្រាប់ការជំនុំជម្រះទាំងបួនដំបូង[៨៣] និងបញ្ជីកែសម្រួលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ដែលពាក់ព័ន្ធនឹងដំណាក់កាលជំនុំជម្រះក្នុងវគ្គក្រោយៗ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១[៨៤]។

---

សាក្សីមួយចំនួនដែលស្នើឡើងដោយក្រុមមេធាវីការពារក្តីផ្សេងៗទៀត ឯកសារ E9/15 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១។

[៨១] សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារ E93 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១។

[៨២] ព័ត៌មានបន្ថែមរបស់ អៀង ធីរិទ្ធ ចំពោះបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះទាំងបួនដំបូង ឯកសារ E93/1 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១។ ចំណាត់ថ្នាក់សាក្សី និងអ្នកជំនាញដែលស្នើឡើងសម្រាប់សវនាការបឋម ឯកសារ E93/2 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១។ ព័ត៌មានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះទាំងបួនដំបូង និងសំណើសុំការគូសបញ្ជាក់អំពីចំណងជើងប្រធានបទទីបួន "គោលនយោបាយនៃកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E93/2/1 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង នៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារ E93/3 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។ សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ឯកសារ E93/4 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។

[៨៣] ព័ត៌មានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះទាំងបួនដំបូង ឯកសារ E108/1 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធៈ បញ្ជីកែសម្រួលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងដំណាក់កាលទាំងបួនដំបូង ឯកសារ E108/1.1 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១។

[៨៤] ព័ត៌មានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងដំណាក់កាលក្រោយៗ ឯកសារ E108/2 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ

### ៤.១.៤ អង្គហេតុដែលមិនមានការតវ៉ា

៣០. ទោះបីជាជនជាប់ចោទ អៀង សារី ពិតជាបានយល់ស្របជាមួយនឹងអង្គហេតុខ្លះ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយក៏ដោយ ក៏ពុំមានការយល់ស្របគ្នាជារួមរវាងភាគីនានាទៅលើអង្គហេតុណាមួយនៅក្នុងដីកាដំណោះស្រាយនោះដែរ[៨៥]។

### ៤.១.៥ សំណើសុំបំពេញកិច្ចស៊ើបសួរ

៣១. ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានធ្វើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរមួយចំនួន រួមទាំងសំណើសុំឲ្យស៊ើបសួរលើការចោទប្រកាន់អំពីការជ្រៀតជ្រែកដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសកម្មភាពរបស់ អ.វ.ត.ក ផងដែរ[៨៦]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចច្រានចោលសំណើសុំទាំងអស់ លើកលែងតែសំណើសុំមួយប៉ុណ្ណោះ[៨៧]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ការលើកឡើងផ្សេងៗរបស់

---

៣ក៖ បញ្ជីកែសម្រួលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងដំណាក់កាលក្រោយៗ ឯកសារ E108/2.1 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។

[៨៥] អំពើដែលភាគីទទួលស្គាល់រួមគ្នា ឯកសារ E9/17 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១។ សេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ជូនអង្គជំនុំជម្រះសាលាដំបូងឆ្លើយតបទៅនឹងដីកាបង្គាប់ឲ្យដាក់បញ្ជីរួមនៃអង្គហេតុដែលគ្មានការជំទាស់ ឯកសារ E9/20 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១។ សារណាបឋមទាក់ទងនឹងអង្គហេតុដែលមិនមានការតវ៉ាគ្នា ឯកសារ E9/19 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងអង្គហេតុដែលមិនជំទាស់តវ៉ា ឯកសារ E9/21 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១។

[៨៦] *សូមមើល ឧ.* សំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥ ឯកសារ E82 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១។ សំណើរួមលើកទី១ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ឯកសារ E88 ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សំណើសុំឲ្យមានវិធានការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E189 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២។ សំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ឯកសារ E219 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២។

[៨៧] សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២៣។ សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលស្នើសុំឲ្យមានចំណាត់ការជាបន្ទាន់ចំពោះរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង (ឯកសារ E219) ឯកសារ E219/3 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៧។ សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ២៣ និង ៣២។ *បញ្ជាក់ដោយ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំង

នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសារព័ត៌មានដែលបានចាត់ទុកជនជាប់ចោទ នួន ជា ថាជា "ឃាតករ" និងជា "ជនដៃដល់នៃអំពើប្រល័យពូជសាសន៍" មិនស្របជាមួយនឹងគោលការណ៍នៃការសន្មតថាគ្មានទោសនោះទេ។ ក្រុមមេធាវីការពារក្តីក៏មានការព្រួយបារម្ភផងដែរថា ការលើកឡើងទាំងនេះដែលតាមការចោទប្រកាន់ថា ត្រូវបានថ្លែងឡើងដោយមន្ត្រីសាធារណៈជាន់ខ្ពស់មួយរូបនេះ អាចមានផលប៉ះពាល់ទៅលើមតិសាធារណៈដែលជាការមិនអាចទទួលយកបាន។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការលើកឡើងបែបនេះពុំអាចមានឥទ្ធិពលទៅលើអង្គជំនុំជម្រះសាលដំបូង ឬទៅលើចៅក្រមណាមួយនៃអង្គជំនុំជម្រះនេះនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនឡើយ[៨៨]។ អង្គជំនុំជម្រះសាលាដំបូង បានឯកភាពតាមសំណើរបស់ជន-ជាប់ចោទ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរថ្មីៗ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងការចោទប្រកាន់អំពីការបំភិតបំភ័យសាក្សីផងដែរ[៨៩]។ ក៏ប៉ុន្តែ ក្រោយពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានសាកសួររួចមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មិនតម្រូវឱ្យចាត់វិធានការបន្ថែមណាមួយឡើយ[៩០]។

---

នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (អ.ជ.ត.ក) ឯកសារ E176/2/1/4 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៦៩។ សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការជាបន្ទាន់អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E189/3 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៤។

[៨៨] សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ២៧ *បញ្ជាក់ដោយ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (អ.ជ.ត.ក) ឯកសារ E176/2/1/4 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៦៨។

[៨៩] សំណើលើកទីពីរសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E92 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១។

[៩០] សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១។ កត់សម្គាល់ឃើញថា នួន ជា បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលបណ្តឹងសាទុក្ខរបស់ នួន ជា៖ បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារ E116/1/1 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១។ សេចក្តីសង្ខេបសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (អ.ជ.ត.ក) ឯកសារ E116/1/6 ចុះ

### ៤.១.៦ វត្តមានរបស់ជនជាប់ចោទនៅក្នុងពេលជំនុំជម្រះ

៣២. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទម្នាក់ៗត្រូវបានអនុញ្ញាតឲ្យលះបង់សិទ្ធិមានវត្តមានរបស់ខ្លួននៅក្នុងអំឡុងពេលសវនាការ ក្រោយពីប្រគល់ជូនអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការ ដោយមានហត្ថលេខាយ៉ាងច្បាស់-លាស់ នៅរៀងរាល់ថ្ងៃដែលពួកគេពុំមានបំណងមានវត្តមាន។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនជាប់ចោទមានវត្តមាននៅក្នុងបន្ទប់សវនាការ ប្រសិនបើអង្គជំនុំជម្រះយល់ថា ចាំបាច់ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ឬ ក្នុងករណីដែលវត្តមានរបស់ជនជាប់ចោទមានសារៈសំខាន់ដែលមិនអាចខ្វះបាន ដើម្បីធ្វើឲ្យសវនាការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា ជនជាប់ចោទណាម្នាក់ដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយត្រូវបញ្ជាក់ពីការសម្រេចនេះជាសាធារណៈមុនពេលជនជាប់ចោទនោះចុះទៅបន្ទប់ឃុំខ្លួន នៅខាងក្រោមសាលសវនាការដែលមានគ្រែ និងបំពាក់ទៅដោយគ្រឿងបច្ចេកទេសព័ត៌មានវិទ្យា ដើម្បីអនុញ្ញាតឲ្យគាត់អាចចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍បាន[៩១]។ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការ ពេលខ្លះជនជាប់ចោទបានប្រើប្រាស់សិទ្ធិចូលរួមនៅក្នុងសវនាការ ពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីក្រោមសាលសវនាការ ហើយពេលខ្លះទៀត ពួកគេបានស្នើសុំអវត្តមាននៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ក្រោយពីបានពិចារណាលើរបាយការណ៍របស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យជនជាប់ចោទ អៀង សារី វិលត្រឡប់ទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ១៣, ១៤-១៧, ២០។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (អ.ជ.ត.ក) ឯកសារ E116/1/7 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៨, ៣៣-៣៥, ៣៨។

[៩១] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹង “ការកត់សម្គាល់” របស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E130) ឯកសារ E130/3 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ២ ERN (ជាភាសាអង់គ្លេស) 00749893។

វិញ បើទោះបីជាពុំមានលិខិតលះបង់សិទ្ធិមានវត្តមានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលសវនាការក៏ដោយ[៥២]។

៣៣. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា តម្រូវឲ្យជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់។ ជន-ជាប់ចោទ អៀង សារី បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចនេះ នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ដោយលើកឡើងថា សេចក្ដីសម្រេចនេះមានន័យស្មើនឹងការជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[៥៣]។ ទោះបីជាយ៉ាងនេះក្ដី នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសមិនទទួលយកបណ្ដឹងសាទុក្ខនេះឡើយ[៥៤]។

៣៤. នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ បន្ទាប់ពីទទួលបានអនុសាសន៍ផ្នែកវេជ្ជសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា តម្រូវឲ្យជនជាប់ចោទ អៀង សារី ចូលរួមក្នុងកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនរបស់គាត់នៅខាងក្រោមសាលសវនាការ និងហាមឃាត់មិនឲ្យមានការថតខ្សែអាត់វីដេអូលើរូបគាត់ឡើយ[៥៥]។ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចនេះ[៥៦]។ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣

---

[៥២] សេចក្ដីសម្រេចស្ដីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារ E238/9 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ២៤, ៣២-៣៤, ៣៧។

[៥៣] បណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលជំនុំជម្រះក្ដី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្ដីរបស់គាត់ដោយខ្លួនគាត់ ឯកសារ E130/4/1 ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៦-៨, ១២, ១៤។

[៥៤] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ (អ.ជ.ត.ក) ឯកសារ E130/4/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ទំព័រ ២។

[៥៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ១-៤ និង ១៧-១៩។

[៥៦] បណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់មិនឲ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យថតវីដេអូលើរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឯកសារ E238/9/1/1 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។

ក្រោយពីមរណភាពរបស់ជនជាប់ចោទ អៀង សារី អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលបណ្តឹងសាទុក្ខនេះ[៩៧]។

### ៤.១.៧ កំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា

៣៥. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើកំហុសរបស់ក្រុមមេធាវីការពារក្តី បន្ទាប់ពីការប្រព្រឹត្តិកំហុសដដែលៗរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ជាពិសេស លោក Andrew IANUZZI និងលោក Michiel PESTMAN នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី[៩៨]។ ក្រោយពីមានការព្រមានផ្ទាល់មាត់រួចមក អង្គជំនុំ-ជម្រះសាលាដំបូងបានបញ្ជូនកំហុសរបស់ពួកគេ ទៅគណៈមេធាវីក្នុងប្រទេសនីមួយៗរបស់ពួកគេ និងបានជូនដំណឹងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

៣៦. នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ជាថ្មីម្តងទៀតពីការព្រមានរបស់ខ្លួនចំពោះលោក IANUZZI ។ ប្រតិចារឹកពាក់ព័ន្ធនឹងហេតុការណ៍នេះ ត្រូវបានបញ្ជូនទៅគណៈកម្មាធិការវិន័យនៃនាយកដ្ឋានតុលាការទីមួយ ផ្នែកឧបាស្រ័យរបស់តុលាការកំពូលរដ្ឋញូវយ៉ក[៩៩]។ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ គណៈកម្មាធិការវិន័យនៃនាយកដ្ឋានតុលាការនេះបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង អំពីគោលនយោបាយរបស់គណៈកម្មាធិការចំពោះការព្យួរការស៊ើបអង្កេតលើការចោទប្រកាន់អំពីកំហុសវិជ្ជាជីវៈ ខណៈដែលកិច្ចដំណើរការនីតិវិធី

---

[៩៧] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ*ក្រោយមរណភាព* របស់ អៀង សារី ឯកសារ E238/9/1/5 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣។

[៩៨] សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E214 ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២។ កំហុសនេះរួមទាំងការរំលោភបំពានដោយចេតនាលើដីកាសម្រេចរបស់តុលាការ ការបញ្ចេញព័ត៌មានដោយគ្មានការអនុញ្ញាតដល់អ្នកសារព័ត៌មាន នូវឯកសារសម្ងាត់ ឬ សម្ងាត់បំផុត និងការធ្វើសេចក្តីថ្លែងការណ៍មិនគោរពដល់តុលាការ ឬ បើមិនដូច្នោះទេ មិនបានគោរពតាមបទដ្ឋានដែលត្រូវបានទទួលស្គាល់ និងក្រមសីលធម៌វិជ្ជាជីវៈមេធាវី។ *សូមមើលផងដែរ* កំហុសវិជ្ជាជីវៈរបស់មេធាវីនៃគណៈមេធាវីរបស់លោក/លោកស្រី ឯកសារ E214/1 ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ២-១១។

[៩៩] សេចក្តីបន្ថែម៖ ការបន្តការប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់មេធាវីដែលជាសមាជិករបស់គណៈមេធាវីរបស់លោក/លោកស្រី ឯកសារ E214/4 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២។

ពាក់ព័ន្ធនឹងបញ្ហានេះកំពុងបន្តទៅមុខ[១០០]។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ ក្រោយពីលោក IANUZZI បានលាលែងពីតំណែងជាមេធាវីសម្រាប់ជនជាប់ចោទ នួន ជា រួចមក អង្គជំនុំជម្រះសាលាដំបូង បានស្នើសុំគណៈកម្មាធិការវិន័យនៃនាយកដ្ឋានតុលាការនេះឲ្យពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចរបស់ខ្លួនក្នុងការព្យួរការស៊ើបអង្កេតលោក IANUZZI[១០១]។ អង្គជំនុំជម្រះសាលាដំបូងពុំទទួលបានសេចក្ដីសម្រេចណាមួយលើសំណើសុំ ឬ លើអង្គសេចក្ដីនេះទេ ហើយក៏ពុំទទួលបានការជូនដំណឹងណាមួយ អំពីលទ្ធផលនៃបណ្ដឹងមុនៗពីគណៈមេធាវីនៃប្រទេសទាំងពីរនោះដែរ។

### ៤.១.៨ កិច្ចប្រជុំស្ដីពីការរៀបចំសវនាការ

៣៧. កិច្ចប្រជុំស្ដីពីការរៀបចំសវនាការត្រូវបានរៀបចំធ្វើនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ដោយនៅក្នុងកិច្ចប្រជុំនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សវនាការនឹងប្រព្រឹត្តទៅតាមលំដាប់លំដោយអង្គហេតុដូចខាងក្រោម៖

១. រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ។

២. តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងតួនាទីទាំងនោះ។

៣. តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគាត់តាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់គាត់ និងខ្សែបណ្ដាញទំនាក់ទំនងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក ។

៤. គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្ដីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[១០២]។

---

[១០០] លិខិតពាក់ព័ន្ធនឹង “ករណីលោក Andrew Ianuzzi សំណុំរឿងលេខ 2012.1596” ឯកសារ E214/4/1 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[១០១] សេចក្ដីបន្ថែមទីពីរ៖ ការបន្តប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់មេធាវីដែលជាសមាជិករបស់គណៈមេធាវីរបស់លោក/លោកស្រី ឯកសារ E214/5 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣។

[១០២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៥២។

៣៨. នៅថ្ងៃទី ១៧ និងថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ កិច្ចប្រជុំស្តីពីការរៀបចំសវនាការមួយចំនួនទៀតត្រូវបានរៀបចំធ្វើឡើង ដើម្បីផ្តល់លទ្ធភាពឱ្យរៀបចំផែនការសម្រាប់ដំណាក់កាលជំនុំជម្រះដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការនាពេលខាងមុខដែលបានរៀបចំឡើង ដើម្បីធ្វើឱ្យការជំនុំជម្រះកាន់តែមានប្រសិទ្ធភាព[១០៣]។

## ៤.២ សវនាការបឋម

៣៩. សវនាការបឋមត្រូវបានរៀបចំធ្វើឡើង ចាប់ពីថ្ងៃទី ២៧ ដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ដោយបានពិភាក្សាទៅលើអង្គហេតុនានា រួមមានអញ្ញត្រកម្ម និងបញ្ជីឈ្មោះបណ្តោះអាសន្នស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ[១០៤]។

## ៤.៣ ការបំបែកកិច្ចដំណើរការនីតិវិធី

៤០. ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ទៅជាសំណុំរឿងតូចៗ។ អង្គជំនុំជម្រះបានសម្រេចថា ផ្នែកទីមួយនៃសំណុំរឿង០០២ ដែលក្រោយមកហៅថា "សំណុំរឿង ០០២/០១" ត្រូវមាន៖

(ក) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។

(ខ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញខាងនយោបាយ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដោយ

---

[១០៣] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំ សវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះ ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការដែលបានគ្រោងទុកនាពេលខាងមុខ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២។ *សូមមើលផងដែរ* សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) ឯកសារ E218.1 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២។

[១០៤] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ទំព័រ ២, ១៧។

ហេតុថា អង្គហេតុទាំងនេះពាក់ព័ន្ធ នឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)[១០៥]។

៤១. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មមួយចំនួនបន្ថែមទៀត នៅក្នុងសំណុំរឿង ០០២/០១[១០៦]។ នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចពង្រីកវិសាលភាពនៃការជំនុំជម្រះ ដោយដាក់បញ្ចូលការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ប៉ុន្តែបដិសេធមិនដាក់បញ្ចូលការសម្លាប់អ្នកដែលត្រូវបានជម្លៀសនៅតាមទីតាំងនានាក្នុងស្រុកកំពង់ត្រឡាចលើ ឬ មន្ទីរសន្តិសុខ ស-២១ និងកន្លែងសម្លាប់មនុស្សនៅជើងឯក ដែលពាក់ព័ន្ធនោះទេ[១០៧]។ សហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

---

[១០៥] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៣។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ ឯកសារ ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ២។ សូមមើលផងដែរនូវ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) ឯកសារ E124/7.2 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[១០៦] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ឯកសារ E163 ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២។ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា។ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅនឹង អៀង សារី។ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់ញត្តិសុំលុបចោលសំណើសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញាដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១។ វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានលើកយកមកពិភាក្សាសាជាថ្មីនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំស្តីពីការរៀបចំសវនាការដែលបានធ្វើឡើង កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២។

[១០៧] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការ

សាលាដំបូង នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដោយបានស្នើសុំឲ្យកែប្រែសេចក្តីសម្រេចនេះ ដើម្បីដាក់បញ្ចូលការចោទប្រកាន់ចំពោះអង្គហេតុនានា ដែលត្រូវបានបដិសេធនៅក្នុងសំណុំរឿង ០០២/០១[១០៨]។ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចាត់ទុកជាមោឃៈនូវសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនេះទាំងមូល ដោយបានអះអាងថាសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ លើកដំបូងនៅក្នុងខែ កញ្ញា ឆ្នាំ ២០១១ និងសេចក្តីសម្រេចពាក់ព័ន្ធនាពេលក្រោយៗមកទៀត ពុំមានភាពច្បាស់លាស់ និងគ្មានសំអាងហេតុ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ និងកំណត់វិសាលភាពនៃសំណុំរឿង០០២/០១ ដោយពុំបានផ្តល់ឱកាសគ្រប់គ្រាន់ឲ្យភាគីធ្វើសេចក្តីសន្និដ្ឋាន ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាបញ្ហានេះសាជាថ្មី ក្រោយពីពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគី[១០៩]។

៤២. អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់លើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដោយបានផ្តល់សំអាងហេតុក្នុងរយៈពេលមួយខែក្រោយមក[១១០]។ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីលើបញ្ហានេះរួចមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វានៅតែជាប្រយោជន៍នៃយុត្តិធម៌ដដែល ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីនេះ ហើយបានសម្រេចកំណត់វិសាលភាពនៃការជំនុំជម្រះលើកទីមួយក្នុងសំណុំរឿង ០០២ នេះត្រឹមការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី ១ និងដំណាក់កាលទី ២ និងការសម្លាប់មនុស្សដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ។ អង្គជំនុំជម្រះ

---

ដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ១-៣។

[១០៨] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II) ឯកសារ E163/5/1/1 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៣។

[១០៩] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (អ.ជ.ត.ក) ឯកសារ E163/5/1/13 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤៨-៥០។

[១១០] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

សាលាដំបូងបានយល់ឃើញថា សេចក្តីសម្រេចនេះបង្កើតឲ្យមានតុល្យភាពរវាងកត្តានានាដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល ជាមួយនឹងភាពចាំបាច់ដើម្បីធានាលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចេញសាលក្រមមួយនៅក្នុងសំណុំរឿង ០០២ ឲ្យបានទាន់ពេលវេលា។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញទៀតថា ការបន្ថែមមន្ទីរសន្តិសុខ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងពុំផ្តល់ប្រយោជន៍អ្វីធំធេងដល់គោលបំណងស្តីពីភាពជាតំណាងសមស្រប នៅក្នុងការជំនុំជម្រះដំណាក់កាលទីមួយនេះទេ ហើយការពង្រីកបន្ថែមលើវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងអាចប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះ ក្នុងការចេញសាលក្រមឲ្យបានទាន់ពេលវេលា[១១១]។

៤៣. នៅថ្ងៃទី ១០ និងថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា និងជនជាប់ចោទ នួន ជា បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយដាក់បញ្ចូលមន្ទីរសន្តិសុខស-២១ ខណៈពេលដែលជនជាប់ចោទ នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកសេចក្តីសម្រេចនេះជាមោឃៈទាំងស្រុងតែម្តង ឬ បើមិនដូច្នោះទេ អង្គជំនុំជម្រះសាលាដំបូងត្រូវពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយដាក់បញ្ចូលបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅតាមសហករណ៍ និងការដ្ឋានធ្វើការ[១១២]។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ក្នុងពេលរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ អង្គជំនុំជម្រះនឹងពុំពន្យារពេលសម្រាប់ការបញ្ចប់

---

[១១១] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១២២, ១៤១, ១៤៧។

[១១២] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/2/1 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣។ បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹង សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីបីលើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/4/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ (អ.ជ.ត.ក)ឯកសារ E284/2/1/2 ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣។

កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ នោះទេ[១១៣] លើកលែងតែមានការបង្គាប់ពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសង្ខេបនៃសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី។ ទោះបីជាបានសម្រេចច្រានចោលខ្លឹមសារនៃបណ្តឹងសាទុក្ខក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ត្រូវចាប់ផ្តើមធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០១ ហើយសំណុំរឿង ០០២/០២ ជាអប្បបរមាត្រូវបញ្ចូលនូវបទចោទនានា ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ការដ្ឋានធ្វើការ សហករណ៍ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[១១៤]។ សំអាងហេតុទាំងមូលនៃសេចក្តីសម្រេចនេះ បានចេញនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣[១១៥] ក្រោយពេលបញ្ចប់សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០១ ប៉ុន្តែមុនពេលកិច្ចប្រជុំស្តីពីការរៀបចំសវនាការដែលគ្រោងធ្វើឡើងដើម្បីពិចារណាលើបញ្ហានានាដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ បានចាប់ផ្តើមធ្វើកាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣។

## ៤.៤ សវនាការលើអង្គសេចក្តី

៤៤. នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ សវនាការលើអង្គសេចក្តីត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់[១១៦]។ នៅថ្ងៃទី ២២ ខែ វិច្ឆិកា

---

[១១៣] ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទ នៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១០។

[១១៤] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ សេចក្តីសង្ខេបនៃសំអាងហេតុ (អ.ជ.ត.ក) ឯកសារ E284/4/7 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ១១-១៣។

[១១៥] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ (អ.ជ.ត.ក) ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ២៨-៧៦។

[១១៦] ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១៦-៣៦ ទំព័រ ៣៧-៦៤ និងទំព័រ ៦៥-១៣៣។

ឆ្នាំ ២០១១ ជនជាប់ចោទ នួន ជា បានធ្វើសេចក្តីសន្និដ្ឋានតបរបស់ខ្លួន[១១៧] ហើយជនជាប់ចោទ អៀង សារី[១១៨] និង ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានតបនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១[១១៩]។

៤៥. សវនាការដេញដោលលើភ័ស្តុតាងបានបញ្ចប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។ ការជំនុំជម្រះ រួមទាំងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល បានចំណាយពេលសរុបចំនួន ២២២ ថ្ងៃ នៃថ្ងៃសវនាការ។ បុគ្គលចំនួន ៩២ នាក់ បានផ្តល់ភ័ស្តុតាងនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ដែលក្នុងនោះរួមមាន៖ អ្នកជំនាញចំនួន ០៣ នាក់ សាក្សីអង្គហេតុចំនួន ៥៣ នាក់ សាក្សីអត្តចរិត ចំនួន ០៥ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់។

## ៤.៥ ការដាក់សារណា និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

៤៦. នៅថ្ងៃទី ២៦ និងថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ ភាគីនានាបានដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ពួកគេ[១២០]។

៤៧. នៅចន្លោះថ្ងៃទី ១៦ និងថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ភាគីនានា និងជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

---

[១១៧] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧៦-១១២។

[១១៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៣-៥។ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី អៀង សារី បានបោះបង់សិទ្ធិធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល៖ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១១៧-១៣៣។

[១១៩] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៨-៤៣។

[១២០] សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើសំណុំរឿង ០០២/០១ ឯកសារ E295/6/2 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣។ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/1 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣។ សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ (សំណៅឯកសារចុងក្រោយបានដាក់នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣)។ សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ (សំណៅឯកសារចុងក្រោយបានដាក់នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣)។